ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
FUTABA MICROFINANCE PLC.

# ឱកាសការងារ

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ទទួលបានអាជ្ញាប័ណ្ណផ្លូវការពីធនាគារជាតិនៃកម្ពុជានៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ និងបានចាប់ផ្តើមប្រតិបត្តិការអាជីវកម្មពី **ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦** ដោយសម្រេចបាននូវភាពជោគជ័យ និងការរីកចម្រើន យ៉ាងឆាប់រហ័ស។ ជាក់ស្តែង **ហ្វូតាបា** បានពង្រីកតំបន់ប្រតិបត្តិការរបស់ខ្លួនជាបន្តបន្ទាប់ ដោយបានដាក់ឲ្យដំណើរការ ការិយាល័យសាខាថ្មីបន្ថែមចំនួនបី (៣) ទៀតនៅក្នុងត្រីមាសទីបីនៃឆ្នាំ២០១៦។ បច្ចុប្បន្ន **ហ្វូតាបា** ត្រូវការជ្រើសរើសបុគ្គលិក ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីបម្រើការងារក្នុងមុខតំណែងដូចខាងក្រោម ៖

| មុខតំណែង | ចំនួនជ្រើសរើស | សាខា | ទីតាំងការងារ |
|---|---|---|---|
| មន្ត្រីឥណទានជាន់ខ្ពស់ និង មន្ត្រីឥណទាន | ០២ នាក់ | សាខាការិយាល័យកណ្តាល | រាជធានីភ្នំពេញ |

## ភារកិច្ច និងការទទួលខុសត្រូវ

- ផ្សព្វផ្សាយផលិតផល និងសេវាកម្មរបស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ទៅដល់អតិថិជនសក្តានុពល។
- ធ្វើការសិក្សា វិភាគ វាយតម្លៃលទ្ធភាពសង និងទ្រព្យដាក់ធានារបស់អតិថិជនឲ្យបានត្រឹមត្រូវ។
- រៀបចំរបាយការណ៍ និងសំណើសុំឥណទាន ដើម្បីដាក់ជូននាយកសាខាឬគណៈកម្មាធិការឥណទានពិនិត្យ និងអនុម័ត
- ថែរក្សាទំនាក់ទំនងល្អ ជាមួយអតិថិជនដែលមានស្រាប់ និងស្វែងរក អតិថិជនថ្មីបន្ថែម។
- បញ្ចេញឥណទានទៅតាមផែនការ ដែលបានកំណត់ដោយនាយកសាខា។
- ពង្រឹងគុណភាពនៃការប្រមូល និងដោះស្រាយបញ្ហាយឺតយ៉ាវក្នុងការសងត្រឡប់ឥណទានមកវិញឲ្យបានទាន់ពេល។
- បង្កើនទំនាក់ទំនងជាមួយអាជ្ញាធរក្នុងតំបន់ ដែល គ្រឹះស្ថាន **ហ្វូតាបា** កំពុងធ្វើប្រតិបត្តិការ និងសិក្សាអំពីគូប្រកួតប្រជែងក្នុងតំបន់ ព្រមទាំងរៀបចំផែនការ ដើម្បីទទួលបានចំណែកទីផ្សារបន្ថែម។
- ធ្វើរបាយការណ៍ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ និងប្រចាំខែ ជូនអ្នកគ្រប់គ្រង។

## លក្ខខណ្ឌជ្រើសរើស

- បញ្ចប់ថ្នាក់បរិញ្ញាបត្រ ឬជានិស្សិតកំពុងសិក្សា ផ្នែកទីផ្សារ គ្រប់គ្រង គណនេយ្យ ហិរញ្ញវត្ថុ និងធនាគារ ឬសញ្ញាបត្រដែលមានតម្លៃស្មើ។
- មានជំនាញក្នុងការទំនាក់ទំនង និងដោះស្រាយបញ្ហាជូនអតិថិជន មានភាពស្មោះត្រង់ និងអាចធ្វើការងារជាក្រុម។
- មានចំណេះដឹងភាសាអង់គ្លេស អាចសរសេរ និងនិយាយបានល្អ។
- អាចប្រើប្រាស់កុំព្យូទ័រ Ms Office Word & Ms Excel។
- ចេះបើកបរម៉ូតូ។
- ផ្តល់អាទិភាពដល់អ្នកដែលធ្លាប់បម្រើការងារ នៅរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ និងខេត្តតាកែវ។

អគារលេខ៧៩៥ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
(៨៥៥) ២៣ ២២៤ ៣៣៣, ទូរសារ: (៨៥៥) ២៣ ២២២ ១៣១
info@futabamfi.com.kh www.futabamfi.com.kh Futaba Microfinance Plc.

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ផ្តល់ជូនបុគ្គលិកពេញសិទ្ធិនូវ អត្ថប្រយោជន៍ផ្សេងៗដូចជា៖

| | |
|---|---|
| ១. ផ្តល់ប្រាក់បៀវត្សប្រកួតប្រជែងទៅតាមបទពិសោធន៍។<br>២. ប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំខ្មែរ ១០០% នៃប្រាក់បៀវត្ស។<br>៣. ប្រាក់ឧបត្ថម្ភបុណ្យភ្ជុំបិណ្ឌ ១០០% នៃប្រាក់បៀវត្ស។<br>៤. ការធានារ៉ាប់រងសុខភាពដល់បុគ្គលិក និងសមាជិកគ្រួសារ (ប្តី/ប្រពន្ធ និងកូន២នាក់)។<br>៥. ការធានារ៉ាប់រងគ្រោះថ្នាក់ដល់ជីវិត ២៤ ម៉ោង។<br>៦. ប្រាក់ឧបត្ថម្ភចំណាងដៃ អាពាហ៍ពិពាហ៍បុគ្គលិក។<br>៧. ផ្តល់ប្រាក់កម្ចីដល់បុគ្គលិកក្នុងអត្រាការប្រាក់សមរម្យ។ | ៨. ការឈប់សម្រាកអនុលោមតាមច្បាប់ក្រសួងការងារ និងការឈប់សម្រាកប្រចាំឆ្នាំ។<br>៩. ផ្តល់ឯកសណ្ឋានការងារ។<br>១០. ផ្តល់ស៊ីមកាត និងឈ្នួលទូរសព្ទដៃ។<br>១១. ប្រាក់ឈ្នួលម៉ូតូ $៨០ ក្នុង១ខែ សម្រាប់មន្ត្រីឥណទាន។<br>១២. ប្រាក់រង្វាន់លើកទឹកចិត្ត ទៅមន្ត្រីដែលសម្រេចបានគ្រប់ផែនការ *(Incentive)*។<br>១៣. ប្រាក់ឧបត្ថម្ភ និងសម្ភារៈប្រើប្រាស់ផ្សេងៗ តាមគោលការណ៍កំណត់របស់គ្រឹះស្ថាន **ហ្វូតាបា**។ |

- **រៀបដាក់ពាក្យ៖** បេក្ខជន/បេក្ខនារី ដែលមានចំណាប់អារម្មណ៍បំពេញការងារជាមួយ គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី សូមផ្ញើពាក្យសុំបម្រើការងារ ( **CV និង Cover Letter** ) ជាមួយរូបថត (4x6) ដោយបញ្ជាក់ពីមុខតំណែង និងទីតាំងដែលចង់បម្រើការងារឲ្យបានច្បាស់លាស់ និងយកមកដាក់នៅតាមការិយាល័យសាខារបស់ **ហ្វូតាបា** ឬអាចផ្ញើមកតាមរយៈ Email: Recruitment@futabamfi.com.kh (នាយកដ្ឋានធនធានមនុស្ស)។
- សូមបញ្ជាក់ឲ្យបានច្បាស់លាស់អំពីប្រាក់បៀវត្សរំពឹងទុក។
- **ឈប់ទទួលពាក្យត្រឹម៖** ***ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥ ម៉ោង០៥:០០ល្ងាច*** *(អ្នកដាក់ពាក្យមុនត្រូវបានលើកទឹកចិត្ត)*
- **សម្រាប់ព័ត៌មានបន្ថែម៖**

  សូមទំនាក់ទំនងផ្នែកធនធានមនុស្ស ទូរស័ព្ទលេខៈ 070 479 333 / 070 392 333 ឬចូលទៅកាន់គេហទំព័រ www.futabamfi.com.kh ឬ Facebook Futaba Microfinance Plc.

*(បេក្ខជន ឬបេក្ខនារី ដែលបានដាក់ពាក្យរួចហើយមិនអាចដកពាក្យវិញបានឡើយ)*